- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ២០/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០០

ត្រាស់បង្គាប់

មាត្រា ១._ តែងតាំង :

-ឯកឧត្តម ស៊ឹម សារិត ជាអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

-ឯកឧត្តម ឆាយ សុត ជាអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

មាត្រា ២._ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឲ្យបានសម្រេច ។

មាត្រា ៣._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

**ព្រះរាជក្រឹត្យ នស/រកត/០៥០០/១០៣**

**ស្តីពី**

**លក្ខន្តិកៈដោយឡែក**

**នៃក្របខណ្ឌលេខាធិការរដ្ឋបាល**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

Downloaded from http://www.khmerlaws.com

- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទទួលការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១២ ខែឧសភា ឆ្នាំ ២០០០

**ត្រាស់បង្គាប់**

**ជំពូកទី ១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា ១ .-**

ត្រូវបានបង្កើតក្របខ័ណ្ឌលេខាធិការរដ្ឋបាលរបស់ ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ គ ដូចបានចែងក្នុងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២ .-**

ក្របខ័ណ្ឌលេខាធិការរដ្ឋបាល ដែលជាកម្មវត្ថុនៃលក្ខន្តិកៈដោយឡែកសំរាប់ក្របខ័ណ្ឌលេខាធិការរដ្ឋបាលនេះ ស្ថិតនៅក្រោមឱវាទរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដែលប្រមូលផ្តុំមន្ត្រីរាជការធ្វើការងាររដ្ឋបាលសំរាប់បណ្តាក្រសួង ស្ថាប័ន នានា ។ ឯការវិវត្តន៍របស់មន្ត្រីម្នាក់ៗ គឺស្ថិតនៅក្រោមក្រសួង ស្ថាប័ន សាមី ។

មិនត្រូវបានអនុញ្ញាតអោយបង្កើតក្របខ័ណ្ឌសំរាប់ធ្វើការងារ លេខាធិការរដ្ឋបាលផ្សេងពីក្របខ័ណ្ឌលេខាធិការរដ្ឋបាលឡើយ លើកលែងតែក្រសួងមហាផ្ទៃ ។

**មាត្រា ៣ .-**

មន្ត្រីនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល មានឧបនិស្ស័យសំរាប់បំពេញមុខតំណែងក្នុងលេខាធិការដ្ឋាន និងការទទួលភ្ញៀវ ព្រមទាំងមុខងារផ្នែករដ្ឋបាលធម្មតាទាំងឡាយដែលតម្រូវអោយមានចំណេះដឹងបច្ចេកទេស ឬការយល់ដឹងក្នុងការអនុវត្តន៍ជាក់ស្តែង ។ មន្ត្រីនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ក៏អាចមានឧបនិស្ស័យសំរាប់ត្រួតពិនិត្យលើការងាររបស់បុគ្គលិកនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលផងដែរ ។ មន្ត្រីនៃក្របខ័ណ្ឌលេខាធិ ការរដ្ឋបាល ត្រូវដាក់អោយបំពេញមុខងារក្នុងអង្គភាពរដ្ឋបាលកណ្តាល ឬ ខេត្តក្រុង ស្របតាមមាត្រា ៥ នៃ ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។ មន្ត្រីក្នុងក្របខ័ណ្ឌនេះ ក៏មានឧបនិស្ស័យសំរាប់បំពេញមុខតំណែង នៅក្នុងគ្រឹះ ស្ថានសាធារណៈរដ្ឋបាលផងដែរ ។

Downloaded from http://www.khmerlaws.com

## ជំពូកទី ២
## ឋានន្តរសក្តិ

**មាត្រា ៤ ._**

ក្របខ័ណ្ឌលេខាធិការរដ្ឋបាល ៣ ឋានន្តរសក្តិ :

- នាយលេខាធិការរដ្ឋបាល : មាន ០៦ ថ្នាក់
- លេខាធិការរដ្ឋបាលដើមខ្សែ : មាន ១០ ថ្នាក់
- លេខាធិការរដ្ឋបាល : មាន ១៥ ថ្នាក់ ។

## ជំពូកទី ៣
## ការជ្រើសរើស

**មាត្រា ៥ ._**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌលេខាធិការរដ្ឋបាល ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែង ដែលរៀបចំឡើងដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដោយមានការចូលរួមពីស្ថាប័នសាមី ក្នុងចំណោមបេក្ខជនមន្ត្រីរាជការ និង ឬក្នុងចំណោមសិស្ស និស្សិត ។ ចំនួនតំណែងក្នុងការជ្រើសរើស សំរាប់បេក្ខជនជាមន្ត្រីរាជការ និងសំរាប់បេក្ខជនជាសិស្ស និស្សិតត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា ៦ ._**

ការប្រឡងប្រជែងក្នុងចំណោមសិស្ស និស្សិត ត្រូវបើកចំហចំពោះបេក្ខជនដែលមានអាយុច្រើនបំផុត ២៥ ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ហើយដែលមានសញ្ញាប័ត្រទាបបំផុតសមមូលមធ្យមសិក្សាប័ត្រភាគទី ២ ។ អាយុនេះ អាចរំកិល ពី ២៥ ឆ្នាំឡើងដល់ ៣០ ឆ្នាំ ស្របតាមមាត្រា១១ នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

ការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវបើកចំហចំពោះមន្ត្រីរាជការទាំងឡាយ ស្ថិតក្នុងក្របខ័ណ្ឌ ប្រភេទ ឃ ដែលបានបំពេញការងារ ៥ ឆ្នាំ ពេញលេញគិតរួចមកហើយ ។ ចំពោះមន្ត្រីក្នុងក្របខ័ណ្ឌ ដែលមានសញ្ញាប័ត្រសមមូលនឹងមធ្យមសិក្សាប័ត្រភាគទី ២ អាចប្រឡងប្រជែងចូលក្នុងក្របខ័ណ្ឌនេះបាន ដោយពុំគិតលក្ខខ័ណ្ឌអតីតភាពការងារ និងអាយុឡើយ ។

## ជំពូកទី ៤
## កម្មសិក្សា សាកល្បង និង ការតាំងស៊ប់

**មាត្រា ៧ ._**

បេក្ខជនដែលត្រូវបានជ្រើសរើស តាមរយៈការប្រឡងប្រជែង ក្នុងចំណោមមន្ត្រីរាជការ និង ឬ ក្នុងចំណោម សិស្ស និស្សិត ចាំបាច់ត្រូវឆ្លងកាត់រយៈពេលធ្វើកម្មសិក្សាមួយ ដែលមានរយៈពេលដូចខាងក្រោមនេះ ៖

Downloaded from http://www.khmerlaws.com

១- ១២ ខែ ចំពោះមន្ត្រីរាជការដែលត្រូវបានជ្រើសរើសចេញមកពីសិស្ស និស្សិត ។

២- ៦ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុននេះពុំស្ថិតក្នុងក្របខ័ណ្ឌថ្នាក់ងាររដ្ឋបាល ។

ចំពោះមន្ត្រី ដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការហើយ ដែលពីមុននេះស្ថិតក្នុងក្របខ័ណ្ឌថ្នាក់ងាររដ្ឋបាលពុំចាំបាច់ឆ្លងកាត់កម្មសិក្សាសាកល្បងឡើយ ។

ក្រោយពេលធ្វើកម្មសិក្សាសាកល្បង មន្ត្រីដែលចែងក្នុងចំណុចទី១ និងទី២ ខាងលើ ត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិលេខាធិការរដ្ឋបាល ឬ ក្នុងករណីចាំបាច់អាចត្រូវបានអនុញ្ញាតអោយធ្វើកម្មសិក្សាបន្តបន្ថែម ដែលមានរយៈពេលអតិបរមាត្រឹម ១២ ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី ១ និង ៦ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី ២ ។ មន្ត្រីដែលពុំមានបានទទួលជោគជ័យក្នុងការធ្វើកម្មសិក្សាបន្ថែមនេះ ត្រូវបានលុបឈ្មោះចោលប្រសិនបើចេញមកពីសិស្ស និស្សិត ឬ មួយបញ្ចូលទៅក្របខ័ណ្ឌដើមរបស់ខ្លួនវិញ ប្រសិនបើចេញមកពីមន្ត្រីរាជការ ដោយគិតបញ្ចូលរាប់អតីតភាពការងារ ។ ករណីខាងលើទាំងនេះត្រូវសំរេចដោយប្រកាសរបស់ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ តាមសំណើរបស់ក្រសួង ស្ថាប័នសាមីដោយបញ្ជាក់នូវមូលហេតុ ។

មន្ត្រីលេខាធិការរដ្ឋបាល ដែលបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមសិស្ស និស្សិត ត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ ១៥ នៃឋានន្តរស័ក្តិលេខាធិការរដ្ឋបាល ។

មន្ត្រីលេខាធិការរដ្ឋបាល ដែលបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវបញ្ចូលទៅក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់បើបន្ទាប់ ពីសន្ទស្សន៍ចាស់របស់សាមីខ្លួន ។

ការតែងតាំងជាមន្ត្រីលេខាធិការរដ្ឋបាលកម្មសិក្សា និងការតាំងស៊ប់ក្នុងឋានន្តរស័ក្តិលេខាធិការរដ្ឋបាលនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ត្រូវធ្វើឡើងដោយប្រកាសរបស់ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ តាមសំណើរបស់ស្ថាប័នសាមី ។

## ជំពូកទី ៥
## ការតែងតាំង

**មាត្រា ៨ ._**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌលេខាធិការរដ្ឋបាលរួចហើយ មន្ត្រីរាជការទាំងនេះ អាចត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរណាមួយ ដែលស្របជាមួយឋានន្តរស័ក្តិរបស់ខ្លួន ដោយប្រកាសរបស់ រដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមី តាមបែបបទដូចបានកំណត់ក្នុងមាត្រា ២៨ នៃព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

Downloaded from http://www.khmerlaws.com

មាត្រា ៩ ._

មន្ត្រីនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលអាចផ្លាស់ប្តូរ ពីក្រសួង ស្ថាប័នមួយ ទៅក្រសួង ស្ថាប័នមួយទៀត តាមការស្នើសុំរបស់សាមីខ្លួន ឬ តាមតំរូវការការងារ ដោយមានការឯកភាពរបស់ក្រសួង ស្ថាប័នសាមីទាំងពីរ និងដោយមានការយល់ព្រមពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

ការផ្លាស់ប្តូរនេះជាគោលការណ៍ អាស្រ័យដោយតំណែងដែលមាននៅទំនេរ ក្នុងក្រសួង ស្ថាប័នមួយទៀត ឬដោយសំណូមពរការងារចាំបាច់ ។

## ជំពូកទី ៦

## ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរសក្តិ

មាត្រា ១០ ._

មន្ត្រីនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ត្រូវបានតម្លើងថ្នាក់ទៅតាមលក្ខខ័ណ្ឌដូចបានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម ៖

-គោរពវិន័យការងារបានត្រឹមត្រូវ

-សម្រេចបានល្អនូវភារកិច្ចដែលប្រគល់អោយ

-មានសីលធម៌ល្អ ។

ការឡើងថ្នាក់ នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង ១ ភាគ ៤ តាមវេនអតីតភាព ហើយត្រូវសំរេចដោយប្រកាសរបស់ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មាត្រា ១១ ._

គោលការណ៍នៃការតម្លើងឋានន្តរស័ក្តិ ត្រូវតម្លើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬក្នុងករណីចាំបាច់ត្រូវតម្លើងទៅក្នុងថ្នាក់ ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ការតម្លើឋានន្តរស័ក្តិ ត្រូវអនុវត្តអោយបានស្របជាមួយចំនួនតំណែង ដែលមានទំនេរនៅក្នុងឋានន្តរស័ក្តិនោះ ហើយត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬ តាមរយៈការប្រឡងប្រជែងដោយរក្សាគោលការណ៍ភាគរយ ៖

Downloaded from http://www.khmerlaws.com

-ឋានន្តរស័ក្តិនាយលេខាធិការរដ្ឋបាល = ៥ ភាគរយ

-ឋានន្តរស័ក្តិលេខាធិការរដ្ឋបាលដើមខ្សែ = ២៥ ភាគរយ

-ឋានន្តរស័ក្តិលេខាធិការរដ្ឋបាល = ៧០ ភាគរយ ។

ការតម្លើងឋានន្តរស័ក្តិ ត្រូវសំរេចតាមប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មាត្រា ១២ ._

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិលេខាធិការរដ្ឋបាលដើមខ្សែ គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិលេខាធិការរដ្ឋបាល ។ អាចតម្លើងទៅក្នុងឋានន្តរស័ក្តិនាយលេខាធិការរដ្ឋបាល គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ៧ នៃឋានន្តរស័ក្តិលេខាធិការរដ្ឋបាលដើមខ្សែ ។

មាត្រា ១៣ ._

សន្ទស្សន៍សំរាប់ថ្នាក់ ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល និងតម្លៃរាកតា នៃសន្ទស្សន៍ព្រមទាំងរបបលាភការផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

ជំពូកទី ៧

បទប្បញ្ញត្តិដោយឡែក

មាត្រា ១៤ ._

មន្ត្រីក្របខ័ណ្ឌលេខាធិការរដ្ឋបាល ត្រូវដាក់អោយចូលនិវត្តន៍ពេលដល់អាយុ ៥៥ ឆ្នាំ ។

ចំពោះការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

មាត្រា ១៥ ._

មន្ត្រីនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ដែលមានសញ្ញាប័ត្រមធ្យមសិក្សាប័ត្រភាគទី ២ + ២ ឆ្នាំ សិក្សាដោយមានសញ្ញាប័ត្រ ត្រូវបានតម្លើងថ្នាក់មួយថ្នាក់ជាស្វ័យប្រវត្តិ ។

ជំពូកទី ៨

អន្តរប្បញ្ញត្តិ

មាត្រា ១៦ ._

ចំនួនដំបូងនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ត្រូវកសាងចេញពីសមាហរណកម្មនៃមន្ត្រីទាំងឡាយដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌនៅរដ្ឋបាលកណ្តាល និង ខេត្ត ក្រុង ។

ជំពូកទី ៩

អវសានប្បញ្ញត្តិ

មាត្រា ១៧ ._

រាល់បទប្បញ្ញត្តិណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

Downloaded from http://www.khmerlaws.com

មាត្រា ១៨ ._

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ៣១ខែ ឧសភា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានយកសេចក្តីជំរាបជូនសម្តេច

នាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ហត្ថលេខា

ពេជ្រ ម៉ុនធិន

***

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ២៧ អនក្រ.បក

### ស្តីពីការបង្កើតគណកម្មាធិការជាតិរៀបចំកម្មវិធីជាតិនៃសកម្មភាពអភិវឌ្ឍន៍កម្ពុជា

****

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការ ប្រព្រឹត្តិទៅរបស់ក្រសួងផែនការ

Downloaded from http://www.khmerlaws.com